**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀងព្យួរកិច្ចសន្យាការងាររវាង និយោជក និងនិយោជិត

ភាគី "ក" តំណាងនិយោជក និង ភាគី "ខ" តំណាងកម្មករនិយោជិត

ខ្ញុំបាទឈ្មោះ Jiradt Parichatkul តួនាទី ជានាយកគ្រប់គ្រងទូទៅ នៃក្រុមហ៊ុន **វីណា ហុងកុង ខំផេនី អែលធីឌី** (សណ្ឋាគារ ភ្នំពេញ) មានអាសយដ្ឋាន៖ លេខ ៥៣ មហាវិថីមុន្នីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានី ភ្នំពេញ ជាតំណាងនិយោជក ហៅថា ភាគី "ក"។

និង ខ្ញុំបាទឈ្មោះ **កែវ ឡា** តួនាទី ជាប្រធានការិយាល័យជួរមុខ និងជាប្រតិភូបុគ្គលិកនៃក្រុមហ៊ុន **វីណា ហុងកុង ខំផេនី អែលធីឌី** (សណ្ឋាគារ ភ្នំពេញ) មានអាសយដ្ឋាន៖ លេខ ៥៣ មហាវិថីមុន្នីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានី ភ្នំពេញ ជាតំណាងនិយោជិត ហៅថា ភាគី "ខ"។

កិច្ចសន្យាព្យួរការងារនេះ ធ្វើឡើងរវាង ភាគី "ក" តំណាងនិយោជក និង ភាគី "ខ" តំណាងកម្មករនិយោជិត ដោយភាគីទាំងពីរជាតំណាង បានព្រមព្រៀងគ្នាដោយដាក់ព្យួរកិច្ចសន្យាការងារកម្មករនិយោជិត ចំនួន ២២៩ នាក់ ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ៤០៥ នាក់ ដែលបំរើការងារនៅក្នុងក្រុមហ៊ុន **វីណា ហុងកុង ខំផេនី អែលធីឌី** (សណ្ឋាគារ ភ្នំពេញ) សម្រាប់រយះពេល ០១ ខែ ដោយគិតចាប់ ពីថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ២០២០ រហូតដល់ ថ្ងៃទី ២២ ខែ តុលា ឆ្នាំ២០២០ ក្នុងរយះពេលព្យួរកិច្ចសន្យាការងារនេះ ភាគី "ក" តំណាងនិយោជក នៃក្រុមហ៊ុន **វីណា ហុងកុង ខំផេនី អែលធីឌី** (សណ្ឋាគារ ភ្នំពេញ) យល់ព្រមផ្តល់ប្រាក់ឧបត្ថម្ភជូនកម្មករនិយោជិតចំនួន ៥០% នៃប្រាក់ខែគោល ដល់កម្មករនិយោជិតទាំង ២២៩ នាក់ សម្រាប់ ខែ កញ្ញា ឆ្នាំ ២០២០។

ក្រែងពុំប្រាកដយើងខ្ញុំទាំងពីរ ដែលជាតំណាងសូមចុះហត្ថលេខា និងផ្ដិតស្នាមមេដៃជាភស្តុតាង។

ភាគី "ខ" តំណាងកម្មករនិយោជិត

**កែវ ឡា**

ភាគី "ក" តំណាងនិយោជក

VINA (H.K) COMPANY LTD.

**Jiradt Parichatkul**

Scanned with CamScanner